# សេចក្ដីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា សូមឲ្យដោះលែងសកម្មជនសិទ្ធិមនុស្ស ដែលបានចាប់ដាក់ក្នុងពន្ធនាគារព្រៃស

website: www.hoksavann.org

ក្នុងរយៈកាលប៉ុន្មានថ្ងៃកន្លងមកនេះ អាជ្ញាធររាជរដ្ឋាភិបាលខ្មែរបានចាប់សកម្មជនអង្គការសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិល និងអ្នកសារពត៍មាន ដាក់ក្នុងពន្ធនាគារព្រៃស ដោយចោទថាបរិហារកេរ្តិ៍ ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសប្រមុខរាជរដ្ឋាភិបាលខ្មែរ គ្រាន់តែអ្នកទាំងនោះបញ្ចេញមតិរិះគន់អ្នកដឹកនាំ ដែលជាបុគ្គលសាធារណៈប៉ុណ្ណោះ ។ ដោយប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា ដែលហាមមិនឲ្យមនុស្សបៀតបៀនគ្នា ហើយសកម្មភាពចាប់ទាំងនោះ មានភាពពុំត្រឹមត្រូវ ពុំមានយុត្តិធម៌មានលក្ខណៈជាការបៀតបៀន សូមអំពាវនាវចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា សូមដោះលែងសកម្មជនសិទ្ធិមនុស្សទាំងនោះ គឺលោកម៉ម-សូណង់ដូ, លោករ៉ុង-ឈុន, លោកកឹម-សុខា, លោកប៉ាង-ងួនទៀង, លោកយ៉េង-វីរៈ និងលោកជាម-ច័ន្ទនី ដែលជាប់ឃុំនិងដាក់គុកក្នុងពន្ធនាគារព្រៃស ជាបន្ទាន់ដោយគ្មានលក្ខខណ្ឌ ។ សកម្មភាពខុសឆ្គងរបស់អាជ្ញាធររាជរដ្ឋាភិបាលនេះ បានធ្វើឲ្យមតិជាតិនិងអន្តរជាតិរិះគន់យ៉ាងខ្លាំងក្លាបំផុត ដោយហេតុផលដូចតទៅនេះ ៖

១- កិច្ចព្រមព្រៀងទីក្រុងប៉ារីសប្រទេសបារាំងឆ្នាំ១៩៩១ ស្តីពីសន្តិភាពប្រទេសកម្ពុជា ចង់ឲ្យខ្មែរបញ្ចប់ជម្លោះ ហើយនាំគ្នាគោរពសិទ្ធិមនុស្ស ។ អង្គការសហប្រជាជាតិបានចំណាយថវិកាអស់រាប់ពាន់លានដុល្លារ ។ ដូច្នេះគេមិនចង់ឲ្យខ្មែរត្រឡប់មករករបបផ្តាច់ការដូចរបបខ្មែរក្រហមនិងបរទេសឈ្លានពានវិញឡើយ ។

២- វិបត្តិនយោបាយក្នុងអាណត្តិទីពបានត្រូវដោះស្រាយដោយបង្កើតរដ្ឋាភិបាលកញ្ចប់ ទោះបីខុសច្បាប់រដ្ឋធម្មនុញ្ញក៏ដោយ ហើយប្រមុខរាជរដ្ឋាភិបាលមានជ័យជំនះទៀត នូវសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ១៩៨៥ អំពីបញ្ហាទឹកដីរវាងកម្ពុជានិងវៀតណាម សូម្បីព្រះមហាក្សត្រក៏មិនជំទាស់នឹងលោកដែរ ។ ឥឡូវនេះប្រមុខរាជរដ្ឋាភិ

បាលមានអំណាចពេញដៃហើយ គួរយកអំណាចនេះបំរើប្រជាពលរដ្ឋ តែបែរជាយកអំណាចនេះទៅចាប់សកម្មជនសិទ្ធិមនុស្សដែលជាអ្នកខំអប់រំប្រជាពលរដ្ឋឲ្យចេះដឹងសិទ្ធិរបស់ខ្លួនទៅវិញ ។

៣- អ្នកនាំពាក្យរបស់រាជរដ្ឋាភិបាលនិយាយថា តុលាការទេដែលបញ្ជាឲ្យចាប់សកម្មជនសិទ្ធិមនុស្សទាំងនោះ ពុំមែនរាជរដ្ឋាភិបាលបញ្ជាឲ្យចាប់ទេ សំដីនេះគ្មានមូលដ្ឋានពិតទេ ព្រោះអ្នកណាក៏ដឹងដែរថា តុលាការខ្មែរមានឥទ្ធិពលពីអ្នកកាន់អំ-ណាច តុលាការខ្មែរមិនហ៊ានធ្វើអ្វីក្រៅពីការធ្វើតាមបំណាងរបស់ប្រមុខរាជរដ្ឋាភិបាល ព្រោះមានភស្តុតាងជាក់ស្តែងគ្រប់គ្រាន់ គឺបើបក្សប្រឆាំងនិងអ្នកដទៃទៀតដាក់ពាក្យប្តឹងប្រមុខរាជរដ្ឋាភិបាល តុលាការដដែលនេះទាត់ចោលដោយបដិសេធមិនដោះស្រាយ ។

៤- សេចក្តីថ្លែងការណ៍និងការសរសេរលើបដា របស់សកម្មជនសិទ្ធិមនុស្សនិងប្រជាពលរដ្ឋ មានលក្ខណៈជាការបញ្ចេញមតិ ពុំមែនជាការបរិហារកេរ្តិ៍ឡើយ ប្រមុខរាជរដ្ឋាភិបាលជាបុគ្គលសាធារណៈត្រូវទទួលការរិះគន់ ។ នេះជាការធម្មតារបស់មេដឹកនាំដែលតែងតែមានការរិះគន់ស្ថាបនាពីសាធារណជនគេមិនដែលចាប់អ្នករិះគន់ដាក់គុកឡើយ ។ នេះគឺជាការរំលោភលើសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ ដែលមាននិយាយក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នត្រង់មាត្រា៤១ ដែលចែងអំពីសិទ្ធិបញ្ចេញមតិ និងប្រឆាំងនូវសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិផង ។ មតិជាតិនិងមតិអន្តរជាតិចោទថា រាជរដ្ឋាភិបាលខ្មែរកំពុងព្យាយាមបំបិទមាត់មតិប្រឆាំង ។

៥- មិនត្រូវយកច្បាប់អ៊ុនតាក់ឆ្នាំ១៩៩៣មកអនុវត្តនៅពេលនេះឡើយ ព្រោះច្បាប់អ៊ុនតាក់គេអនុវត្តតែពេលនោះ ។ បទបរិហារកេរ្តិ៍របស់ច្បាប់អ៊ុនតាក់កាលពីឆ្នាំ ១៩៩៣ ជាបទព្រហ្មទណ្ឌ គេធ្វើឡើងដើម្បីទប់ទល់នឹងពាក្យសំដីរបស់ខ្មែរក្រហមដែលតែងតែបរិហាររិះគន់វៀតណាម និងទប់ទល់ភាគីខ្មែរមួយទៀត ដែលមានវិទ្យុនិងទូរទស្សន៍ គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា កុំឲ្យមានពាក្យសំដីញុះញង់ចាក់ដោត នាំឲ្យខូចកិច្ចព្រមព្រៀង ។

៦- ដំណោះស្រាយវិវាទតាមផ្លូវច្បាប់ ជាការប្រសើរហើយ បើតុលាការមានយុត្តិធម៌ មានភាពឯករាជ្យ ប៉ុន្តែគេដឹងពេញពិភពលោកថា តុលាការខ្មែរពុករលួយនិងស្ថិតនៅក្រោមអទ្ធិពលនៃអ្នកកាន់អំណាច ។ ដូច្នេះទំនាស់ខាងផ្លូវនយោបាយត្រូវតែដោះស្រាយតាមផ្លូវនយោបាយ ឆ្លងតាមការចរចាសំរបសំរួលគ្នា ដោយសន្តិវិធីដូចទំនាស់របស់អ្នកកាន់អំណាចជាមួយគណបក្សប្រឆាំងនៅពេលនេះ ហើយម-ធ្យោបាយនេះធ្លាប់ធ្វើមកហើយ នៅឆ្នាំ១៩៩៣, ១៩៩៨ និងឆ្នាំ២០០៣ ។ បើតុលាការខ្មែរមានយុត្តិធម៌ មានភាពឯករាជ្យវិញ ប្រមុខរាជរដ្ឋាភិបាលខ្មែរ ត្រូវគេកាត់សេចក្តីឲ្យមានទោសរួចទៅហើយ ។ ដូច្នេះហើយបានជាមតិជាតិនិងមតិអន្តរជាតិចោទថា

រាជរដ្ឋាភិបាលខ្មែរបានយកតុលាការជាឧបករណ៍ ដើម្បីកំចាត់គណបក្សប្រឆាំង ។

៧- ត្រង់មាត្រា២៧នៃរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នចែងថា ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ។ ដូច្នេះព្រះមហាក្សត្រមានសិទ្ធិលើកលែងទោសចំពោះជនណាម្នាក់ដែលមានទោស នាយករដ្ឋមន្ត្រីគ្មានសិទ្ធិជំទាស់ឡើយ ព្រោះសិទ្ធិជំទាស់នេះគ្មានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ ។

៨- ត្រូវយកពាក្យរិះគន់របស់មតិជាតិនិងមតិអន្តរជាតិ មកពិចារណា ព្រោះមិត្តបរទេសរិះគន់ក្នុងន័យស្ថាបនា ដោយចង់ឲ្យខ្មែរបានសុខសន្តិភាព កុំចោទគេរិហាថាបរទេសទាំងនោះពុំដឹងការពិតរបស់ខ្មែរទេ ឬពុំគួរពោលថា នេះជាកិច្ចការផ្ទៃក្នុងរបស់ខ្មែរ មិនត្រូវលូកដៃចូលឡើយ ។

៩- ការរំលោភច្បាប់របស់រាជរដ្ឋាភិបាល ដោយយកតុលាការជាឧបករណ៍សំរាប់ចាប់មនុស្សដាក់ក្នុងពន្ធនាគារ តាមពាក្យចោទរបស់មតិជាតិនិងមតិអន្តរជាតិនេះ នាំឲ្យពួកវិនិយោគទុនខ្លាចរអារមិនហ៊ានរកស៊ីនៅប្រទេសកម្ពុជាតទៅទៀត នេះជាការខូចប្រយោជន៍ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

១០- សូមពិចារណាថា កន្លែងណាមានការជិះជាន់ កន្លែងនោះមានការរើបំរះបានសេចក្តីថា បំបាត់អ្នកប្រជាធិបតេយ្យ អ្នកប្រជាធិបតេយ្យនឹងកើតកាន់តែច្រើនឡើង ។ ប្រជាពលរដ្ឋខ្មែរនឹងពិចារណាមើល តើគួរបោះឆ្នោតឲ្យគណបក្សណាទៅអនាគត ដែលធ្វើឲ្យក្រុមគ្រួសារនិងជាតិខ្លួនមានភាពចំរើនរុងរឿង ។

វត្តខ្មែរកាណាដា, ថ្ងៃទី៦ មករា ២០០៦
ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ

❑ ❑

❑